# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វា

**គម្រោងនៃការអនុវត្តន៍របស់សាលា**

សេចក្តីសង្ខេបយោបល់នៃកិច្ចប្រជុំ - ថ្ងៃទី ១២ ២២ ២៣ ២៩ ខែតុលា ថ្ងៃទី៤ និង១២ ខែវិច្ឆិកា ឆ្នាំ២០១៣

---

នៅពេលប្រជុំអំពីគម្រោងនៃការអនុវត្តន៍របស់សាលា នៅថ្ងៃទី ១២ ២២ ២៣ ២៩ ខែតុលា ថ្ងៃទី៤ និង១២ ខែវិច្ឆិកា គេបានសុំឲ្យសមាជិកចូលរួមអង្គប្រជុំ និយាយអំពីអ្វីៗដែលគាត់ឲ្យតម្លៃដល់សាលា និងព័ត៌មានអ្វីដែលគាត់ត្រូវការ នៅពេលពួកគាត់ធ្វើការសម្រេចអំពីការអប់រំសម្រាប់កូន។ ខាងក្រោមនេះគឺជាសេចក្តីសង្ខេបអំពីមតិយោបល់ដែល មាតាបិតា ក្រុមគ្រួសារ និងសមាជិករបស់សហគមន៍ បានផ្តល់ឲ្យ។ បញ្ជីនេះមិនមានអ្វីៗដែលបានលើកយកមកពិភាក្សាទាំងអស់នោះទេ ប៉ុន្តែវាជាការឆ្លុះបញ្ចាំងអំពីសំណូមពរដែលសមាជិកចូលរួមបានផ្តល់ឲ្យ។ សូមទាក់ទងមកយើងខ្ញុំតាមរយៈអ៊ីមែល performanceframework@philasd.org ***ដើម្បីផ្តល់សំណូមពរបន្ថែមទៀត ឬដើម្បីជ្រាបព័ត៌មានបន្ថែម។***

១. ជួលបុគ្គលិក៖ មាន បណ្ណារក្ស អ្នកផ្តល់ឱវាទ គិលានុបដ្ឋាក ដែលមានវិញ្ញាបនប័ត្រ ការជ្រើសរើសកន្លែង កម្រិតនៃចំនួនសិស្សសម្រាប់គ្រូម្នាក់ៗ

២. អ្នកអប់រំដែលមានប្រសិទ្ធិភាព៖ នាយកសាលា និងគ្រូ ដែលមានប្រសិទ្ធិភាព ស្ថានភាពនៃសញ្ញាប័ត្រ ឱកាសនិងការចូលរួមក្នុងការហ្វឹកហ្វឺនផ្នែកការងារ ការរក្សាគ្រូទុក ចំនួនឆ្នាំធ្វើការនៅសាលា ចំនួនឆ្នាំធ្វើការនៅក្រសួង

៣. កម្មវិធីសិក្សា និងការបង្ហាត់បង្រៀន៖ ឯកសារនៃកម្មវិធីសិក្សា និងការរៀបចំឲ្យត្រូវតាមមុខវិទ្យាសំខាន់ៗទូទៅរបស់រដ្ឋ លក្ខណៈហ្មត់ចត់នៃកម្មវិធីសិក្សា ការឆ្នៃប្រឌិតនៃការបង្ហាត់បង្រៀន

៤. ជោគជ័យរបស់សិស្ស៖ កម្រិតនៃការទទួលជោគជ័យរបស់សិស្សដែលលើសពីលទ្ធផលនៃការប្រឡងទូទៅ។ កម្រិតដែលបង្ហាញពីសិស្សានុសិស្សដែលទទួលការអប់រំពិសេស ឬស្ថានភាពនៃសិស្សដែលត្រូវការរៀនភាសាអង់គ្លេស ចំណេះដឹងក្នុងការគិតស៊ីជម្រៅ ការឆ្នៃប្រឌិត ការសិក្សាមុខវិទ្យាផ្សេងៗដែលលើសពី អង់គ្លេស និងគណិតវិទ្យា។

៥. ការរីកចម្រើន៖ ការរីកចម្រើននៃលទ្ធផលគ្រប់កម្រិតទាំងអស់ បង្ហាញពីការរីកចម្រើនក្នុងកម្រិតស្ទាត់ជំនាញ

៦. សមភាព៖ ធ្វើការប្រៀបធៀបដោយយុត្តិធម៌ (មិនមែនចំណាត់ថ្នាក់) ដោយគិតពីភាពខុសគ្នានៃចំនួន សិស្សានុសិស្ស បុគ្គលិកធ្វើការ ថវិកា និងធនធានបន្ថែម - ប្រៀបបធៀប «ផ្លែស្វាយ ទៅនឹងផ្លែស្វាយ»

៧. សន្តិសុខ៖ ទៅតាមជំពូកនៃឧបត្តិហេតុធ្ងន់ធ្ងរ ការបញ្ឈប់បណ្តោះអាសន្ន ញែកឲ្យឃើញភាពខុសគ្នាដើម្បីបង្ហាញពីសិស្សានុសិស្សដែលទទួលការបញ្ឈប់បណ្តោះអាសន្នជាច្រើនដង និងការបញ្ឈប់បណ្តោះអាសន្នដែលទាក់ទងនឹងសន្តិសុខ។ កម្រិតនៃសន្តិសុខដែលប្រមូលបានតាមការស្ទង់មតិ។ ការហ្វឹកហ្វឺនផ្នែកការងារដើម្បីរក្សាសន្តិសុខសាលា។ ផែនការសន្តិសុខរបស់សាលា។ សន្តិសុខនៅតាមតំបន់ជុំវិញ

៨. ការរៀបចំ៖ ប្រើប្រព័ន្ធដែល ងាយស្រួល ងាយយល់ និងផ្តល់ព័ត៌មាន ឲ្យបានជ្រាបពី លទ្ធផល និងការប្រៀបធៀបសាលា។ ប្រើប្រព័ន្ធ ដែលប្រើពណ៌ដើម្បីសង្ខេបពីលទ្ធផលនៃការអប់រំរបស់សាលា

៩. កម្មវិធី៖ បណ្ណាល័យ ដន្ត្រី សិល្បៈ កីឡា សមាគម កម្មវិធី និងសកម្មភាពក្រោយម៉ោងសិក្សា កម្មវិធីរៀនបន្ថែម

១០. ទំនាក់ទំនងជាមួយសហគមន៍៖ មាតាបិតាចូលរួមនៅសាលា។ អត្ថិភាពនៃក្រុមនានារបស់សហគមន៍ ដូចជាសមាគមសាលា និងមាតាបិតា ឬក្រុមប្រឹក្សាសាលា។ ថ្នាក់សម្រាប់មាតាបិតា។ ទំនាក់ទំនងរវាង សាលា និងសហគមន៍ដែលនៅជុំវិញ ដូចជាការសហការរបស់សាលាជាមួយអង្គការនានានៅក្នុងសហគមន៍។ តើបរិយាកាសរបស់សាលា ស្វាគមន៍ក្រុមគ្រួសារ និងសមាជិកសហគមន៍ ឬអត់

១១. ការស្ទង់មតិ៖ យោបល់របស់ សិស្ស មាតាបិតា គ្រូ និងក្រុមនានានៅក្នុងសហគមន៍ កំណត់អាទិភាពនៃកម្រិតរង្វាស់លទ្ធផលនៃការអប់រំ។ អង្កេតមើលសិស្សានុសិស្ស ចាប់តាំងពីថ្នាក់ទី៤ទៅ កែតម្រូវសម្រាប់ក្រុមនៃកម្រិតថ្នាក់នីមួយៗ

១២. ពេលវេលា៖ នៅឆ្នាំក្រោយៗ បញ្ចេញរបាយការណ៍មុនពេលកំណត់នៃលិខិតដាក់ពាក្យសុំចូលរៀននៅវិទ្យាល័យ ដើម្បីឲ្យសិស្សានុសិស្សប្រើរបាយការណ៍នេះ ជាព័ត៌មានដើម្បីធ្វើការសម្រេចចិត្តសម្រាប់លិខិតដាក់ពាក្យសុំចូលរៀនរបស់ពួកគេ

១៣. ការត្រៀមខ្លួនជាស្រេចសម្រាប់ វិទ្យាល័យ និងអាជីព៖ ការចុះឈ្មោះ និងការតស៊ូស្វិតស្វាញ ដើម្បីក្លាយជានិស្សិតមហាវិទ្យាល័យ។ ការចូលរួម និងលទ្ធផលនៃការប្រឡង SAT/ACT

១៤. វត្តមានអវត្តមាន៖ វត្តមានអវត្តមាន និងការមកយឺតពេល របស់គ្រូ និងសិស្សានុសិស្ស

១៥. អាគារ៖ មានបណ្ណាល័យ

១៦. ការរក្សាទុកសិស្ស៖ មក្រិតនៃការរក្សាសិស្សទុកពីដើមដល់ចុងឆ្នាំ ជាពិសេសមុនរដូវប្រឡង

១៧. ផ្សេងៗ៖ ព័ត៌មានល្អៗបន្ថែម ដែលឆ្លុះបញ្ចាំងពី គំនិត គោលបំណង និងតម្លៃ ពិតៗរបស់សាលា

**យោបល់បន្ថែមដែលបានទទួលតាមរយៈអ៊ីមែល**

---

១. អ្នកអប់រំដែលមានប្រសិទ្ធិភាព៖ សមត្ថភាពគ្រូ នៃមុខវិជ្ជាធម្មតា។ បណ្ដឹងតាមផ្លូវការរបស់បុគ្គលិក ដែលប្ដឹងទៅ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា ឬក្រសួងអប់រំនៃរដ្ឋផិនស៊ីលវេញ៉ា។ ពេលវេលាមួយចំនួនរបស់នាយកសាលាសម្រាប់សកម្មភាពក្រៅពីការសិក្សា

២. កម្មវិធីលើកទឹកចិត្ត៖ កម្មវិធីដែលជំរុញឲ្យទទួលបានជោគជ័យកម្រិតខ្ពស់ ក្នុងការប្រឡងទូទៅ

៣. ហិរញ្ញវត្ថុ/ថវិកា៖ ប្រាក់ចំណាយសម្រាប់សិស្សម្នាក់ៗដែលបានបែងចែកតាមប្រភពនៃប្រាក់ជំនួយ (រដ្ឋសហព័ន្ធ រដ្ឋ តំបន់ ឯកជន)។ ថវិកាសម្រាប់មួយថ្នាក់ៗ

៤. អាគារ៖ គុណភាពនៃសម្ភារៈនៅតាមកន្លែង